**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ២១៤២ សហវ.អ.ប

ថ្ងៃ អង្គារ ១១ កើត ខែ ចេត្រ ឆ្នាំរកា ពស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៨

**គោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**<u>កម្មវត្ថុ</u>៖** ករណីសំណើសុំអនុញ្ញាតជាគោលការណ៍ពិនិត្យសម្រេចឱ្យក្រសួងអប់រំ យុវជន និងកីឡាបើកផ្តល់ថវិកាជូនប្រធានមណ្ឌលសំណេរ និងប្រធានមណ្ឌលកំណែដើម្បីទិញហ្វីតសរសេរក្តារខៀនសម្រាប់ដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៧-២០១៨ និងឆ្នាំជាបន្តបន្ទាប់ ។

**<u>យោង</u>៖** លិខិតលេខ ៦៩៥៥ អយក.គល ចុះថ្ងៃទី០៨-១១-២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីចូលរួមគាំទ្រនូវការងារកែទម្រង់វិស័យអប់រំ ជាពិសេស ដើម្បីពង្រឹងការងារគ្រប់គ្រងមណ្ឌលប្រឡង បញ្ចៀសបាននូវបញ្ហាប្រឈមនានាក្នុងដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យ និងសម្រេចដូចខាងក្រោម ៖

១- អនុញ្ញាតជាគោលការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា បើកផ្តល់ថវិកាជូនប្រធានមណ្ឌលសំណេរ និងប្រធានមណ្ឌលកំណែដើម្បីទិញហ្វីតសរសេរក្តារខៀនសម្រាប់តែក្នុងដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៧-២០១៨ និងឆ្នាំជាបន្តបន្ទាប់ រហូតដល់មានការណែនាំជាថ្មី ។

២- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបញ្ចូលមុខសញ្ញាចំណាយទិញហ្វីតសរសេរក្តារខៀននេះ ទៅក្នុងសំណើសុំថវិកាបុរេប្រទានសម្រាប់ចំណាយរៀបចំដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

៣- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំយន្តការផ្ទៃក្នុង ដើម្បីធានាថាការបើកផ្តល់សាច់ប្រាក់ជូនប្រធានមណ្ឌលសំណេរ និងប្រធានមណ្ឌលកំណែ និងការប្រើប្រាស់ហិរញ្ញវត្ថុ សរសេរក្ដារខៀន ប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

-អគ្គនាយកដ្ឋានរតនាគារជាតិ

-ឯកសារ-កាលប្បវត្តិ

លេខ ៨១៥ អយក.ចល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

បញ្ជូនមកៈ-គ្រប់អង្គភាពនិងគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួង

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

ថ្ងៃ សុក្រ ៧កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨

**តប.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អគ្គនាយក**

**ខួន ម៉ាស**